តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia

# ការស្ទង់មតិយុវជនស្តីពីគោលនយោបាយ

## តើពលរដ្ឋវ័យក្មេងយល់ឃើញដូចម្តេចអំពីការអនុវត្តគោលនយោបាយរដ្ឋាភិបាលសំខាន់ៗនៅកម្ពុជា?



*របាយការណ៍សង្ខេប*
*តុលា ២០២២*

# អំពីការស្ទង់មតិយុវជនស្តីពីគោលនយោបាយ

## ហេតុអ្វីចាំបាច់ត្រូវធ្វើការស្ទង់មតិនេះ?

យុវជនត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយថាជាមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ច និងសង្គម ព្រមទាំងជាធនធានមនុស្សដែលមានតម្លៃបំផុតរបស់ប្រទេស។ បទពិសោធន៍ពីបរិបទពិភពលោកបង្ហាញថា ភាពជោគជ័យនៃគោលនយោបាយរបស់រដ្ឋាភិបាលជាញឹកញាប់គឺអាស្រ័យលើរបៀបដែលគោលនយោបាយទាំងនោះជះផលលើពលរដ្ឋដែលជាយុវជន។[១] នៅប្រទេសកម្ពុជា យោងតាមជំរឿនឆ្នាំ២០១៩ ប្រជាជនប្រហែលពីរភាគបីមានអាយុក្រោម៣៥ឆ្នាំ។[២] អ្នកដែលមានអាយុចន្លោះពី ១៥ ទៅ ៣០ឆ្នាំ ដែលត្រូវបានកំណត់ថាជាយុវជនដោយរាជរដ្ឋាភិបាលកម្ពុជា មាន ២៨% នៃចំនួនប្រជាជនសរុប។ កម្ពុជាមានឯកសារគោលនយោបាយ និងយុទ្ធសាស្ត្រជាច្រើន ដែលមានគោលដៅផ្តល់មគ្គុទ្ទេសក៍ដល់ការអភិវឌ្ឍយុវជន និងជំរុញការធ្វើសមាហរណកម្មយ៉ាងពេញលេញរបស់ពួកគេនៅក្នុងផ្នែកសង្គមកិច្ច សេដ្ឋកិច្ច និងនយោបាយរបស់ប្រទេស។ យ៉ាងណាក៏ដោយ ភ័ស្តុតាងពីការស្រាវជ្រាវបង្ហាញថា ទោះបីជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្តី ការប្រែក្លាយគោលដៅគោលនយោបាយទាំងនេះឱ្យជាការពិត គឺនៅតែជាបញ្ហាប្រឈម។[៣] ការសង្កេតបានបង្ហាញថា បញ្ហាប្រឈមរបស់យុវជនកម្ពុជាហាក់កើនឡើងបន្ថែម ដោយសារជំងឺរាតត្បាតសកលកូវីដ-១៩នាពេលថ្មីៗនេះ ការធ្លាក់ចុះនៃសេដ្ឋកិច្ច និងបម្រែបម្រួលទិដ្ឋភាពនយោបាយនៅក្នុងប្រទេស។

ការសិក្សានេះប្រើប្រាស់អភិក្រមដែលកំណត់យកមនុស្សជាសំខាន់ដោយអនុវត្តទស្សនាទាន "**ការស្តាប់យុវជន**" ក្នុងគោលដៅស្វែងយល់ពីយុវជនកម្ពុជា។ ជាពិសេស ការសិក្សានេះចង់ប្រមែប្រមូលព័ត៌មានអំពីក្តីបារម្ភ ក៏ដូចជាតម្រូវការបច្ចុប្បន្ន និងរយៈពេលវែងរបស់យុវជន ជុំវិញសុខភាព ការអប់រំ ការងារ និងការចូលរួមក្នុងវិស័យសង្គមនយោបាយព្រមទាំងទស្សនៈរបស់ពួកគេចំពោះ ការអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហាប្រឈម ក៏ដូចជាការរំពឹងទុកទាំងនេះ។

ជាពិសេស ការសិក្សានេះបានព្យាយាមសម្រេចឱ្យបាននូវគោលបំណងដូចខាងក្រោម៖

- វាស់ស្ទង់ចំណេះដឹងរបស់យុវជនអំពីគោលនយោបាយ និងយុទ្ធសាស្ត្រចម្បងៗរបស់រដ្ឋាភិបាល ទាក់ទងនឹងសុខភាព ការអប់រំ ការងារ និងការចូលរួមរបស់យុវជន
- ស្វែងយល់អំពីបទពិសោធន៍ និងការយល់ឃើញរបស់យុវជនចំពោះការអនុវត្តគោលនយោបាយយុវជន ជុំវិញប្រធានបទដែលបានលើកឡើងខាងលើ និងសិក្សាអំពីអ្វីដែលពួកគេរំពឹងទុកពីគោលនយោបាយទាំងនេះនាពេលអនាគត
- ស្វែងយល់អំពីតម្រូវការ និងក្តីបារម្ភរបស់យុវជន ពាក់ព័ន្ធនឹងការអប់រំ ហិរញ្ញវត្ថុ ការងារ សុខភាព និងការចូលរួមរបស់ពួកគេ
- ផ្អែកលើទិន្នន័យទទួលបានពីការស្ទង់មតិនេះ ធ្វើការសន្និដ្ឋាន ហើយផ្តល់ជាធាតុចូលសម្រាប់គោលនយោបាយ កម្មវិធី និងគម្រោងអភិវឌ្ឍន៍នានា ដោយគិតគូរទៅដល់ភាពផ្សេងគ្នានៃបទពិសោធន៍ និងទស្សនៈរបស់យុវជនដែលមានភេទ កត្តាភូមិសាស្ត្រ និងសេដ្ឋកិច្ចសង្គមខុសៗគ្នា។

---

[១] ធនាគារពិភពលោក របាយការណ៍ស្តីពីការអភិវឌ្ឍរបស់ធនាគារពិភពលោក៖ ការអភិវឌ្ឍន៍ និងមនុស្សជំនាន់ក្រោយ (ធនាគារពិភពលោក ឆ្នាំ២០០៧); USAID យុវជននៅក្នុងគោលនយោបាយនៃការអភិវឌ្ឍ៖ ការទទួលស្គាល់ឱកាសផ្នែកប្រជាសាស្ត្រ (វ៉ាស៊ីងតោន៖ USAID ឆ្នាំ២០១២)

[២] ក្រសួងផែនការ ជំរឿនប្រជាជនទូទៅនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ (ភ្នំពេញ៖ ក្រសួងផែនការ ឆ្នាំ២០២០)

[៣] ក្រុមការងារប្រចាំប្រទេសរបស់អង្គការសហប្រជាជាតិ ការវិភាគអំពីស្ថានភាពយុវជននៅប្រទេសកម្ពុជា (ភ្នំពេញ៖ UNCT ឆ្នាំ២០០៩); អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ការពង្រឹងសិទ្ធិអំណាចយុវជនក្នុងប្រទេសកម្ពុជានាពេលសព្វថ្ងៃ៖ ការវិភាគអំពីស្ថានភាពយុវជន (ភ្នំពេញ៖ KAPE ឆ្នាំ២០១៤); មជ្ឈមណ្ឌលអភិវឌ្ឍន៍ OECD ការត្រួតពិនិត្យឡើងវិញលើគោលនយោបាយស្តីពីសុខុមាលភាពយុវជននៃប្រទេសកម្ពុជា គម្រោងបរិយាប័ន្នយុវជនរបស់ EU-OECD (បារីស៖ មជ្ឈមណ្ឌលអភិវឌ្ឍន៍ OECD ឆ្នាំ២០១៧)

### តើការស្ទង់មតិត្រូវបានធ្វើឡើងដោយរបៀបណា និង តើនរណាខ្លះបានចូលរួមក្នុងការស្ទង់មតិនេះ?

ការសិក្សានេះបានផ្អែកលើការស្ទង់មតិទល់មុខគ្នាទៅលើប្រជាជនកម្ពុជា ដែលមានអាយុចាប់ពី១៥ ទៅ៣០ ឆ្នាំ ដែលបានធ្វើឡើងជាងម្ភៃថ្ងៃ ក្នុងខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០២១។ ការស្ទង់មតិនេះបានប្រើប្រាស់ជំរឿនប្រជាជនឆ្នាំ២០១៩ ជាក្របខណ្ឌនៃការជ្រើសរើសសំណាក និងបានពឹងផ្អែកលើការយកសំណាកដោយចៃដន្យតាមកម្រិត ដែលមានបួនដំណាក់កាល ដើម្បីធានាថាសំណាកនោះជាការតំណាងថ្នាក់ជាតិ។ យុវជនសរុប ១,៦០០ នាក់ នៅក្នុង ២០០ភូមិ ទូទាំង ២៥រាជធានី-ខេត្តនៃប្រទេសកម្ពុជា បានចូលរួមក្នុងការស្ទង់មតិនេះ។ ក្នុងនោះ ៥០ភាគជាស្ត្រី។ ការសម្ភាសបានធ្វើឡើងនៅក្នុងផ្ទះរបស់អ្នកឆ្លើយតបសម្ភាសន៍ ដោយប្រើប្រាស់ការសម្ភាសផ្ទាល់ខ្លួនដោយមានជំនួយកុំព្យូទ័រ (Computer Assisted Personal Interview)។

## ព័ត៌មានរបស់អ្នកចូលរួមផ្តល់សម្ភាសន៍




### តើសំណួរអ្វីខ្លះដែលត្រូវបានសួរនៅក្នុងការស្ទង់មតិនេះ?

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍យុវជន(ឆ្នាំ២០១១) ផ្តល់នូវក្របខ័ណ្ឌគោលគំនិតសំខាន់ៗសម្រាប់រចនាសម្ព័ន្ធ ក៏ដូចជាខ្លឹមសារនៃកម្រងសំណួរដែលត្រូវបានប្រើប្រាស់នៅក្នុងការស្ទង់មតិនេះ។ កម្រងសំណួរផ្តោតលើការប្រមូលបទពិសោធន៍ ការយល់ឃើញ និងការរំពឹងទុករបស់យុវជនកម្ពុជាទៅលើគោលនយោបាយមួយចំនួនដែលមានផលជះខ្លាំងបំផុតលើពួកគេ ជាពិសេសការអប់រំ សុខភាព ការងារ និងការចូលរួមវិស័យសង្គមនយោបាយ។ កម្រងសំណួរស្ទង់មតិមាន ១១៣សំណួរ ដែលត្រូវបានបែងចែកជា ១០ផ្នែក។ ជាមធ្យម ការសម្ភាសនីមួយៗមានរយៈពេលប្រហែល ៣៥នាទី។

## តើលទ្ធផលនៃការស្ទង់មតិមានអ្វីខ្លះ?

របាយការណ៍សង្ខេបនេះបង្ហាញលទ្ធផលសំខាន់ៗ ដែលទទួលបានពីការស្ទង់មតិយុវជនស្តីពីគោលនយោបាយ ឆ្នាំ២០២១ ព្រមទាំងអនុសាសន៍សម្រាប់រដ្ឋាភិបាល ស្ថាប័នអប់រំ អង្គការសង្គមស៊ីវិល រួមទាំងបុគ្គល និងស្ថាប័នផ្សេងទៀតដែលចាប់អារម្មណ៍លើការលើកកម្ពស់សុខុមាលភាពសង្គម សេដ្ឋកិច្ច និងនយោបាយរបស់យុវជន។ ព័ត៌មានលម្អិតបន្ថែមទាក់ទងនឹងលទ្ធផល ការវិភាគ និងការពិភាក្សា នឹងត្រូវបានបង្ហាញនៅក្នុងរបាយការណ៍បច្ចេកទេសពេលលេញនាពេលខាងមុខ។

### គោលបំណងនៃគោលនយោបាយជាតិស្តីពីការការភិវឌ្ឍយុវជន ឆ្នាំ២០១១

**គោលបំណង៖** “យុវជនមានឱកាសអភិវឌ្ឍសក្តានុពលនៅក្នុងការអប់រំ ការងារ សុខភាព ការចូលរួមធ្វើសេចក្តីសម្រេចចិត្ត និងការចូលរួមចំណែកអភិវឌ្ឍគ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក”។

**គោលដៅ ១៖** ផ្តល់ឱកាសឱ្យយុវជនទទួលបានការអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈប្រកបដោយគុណធម៌ និងសមធម៌។

**គោលដៅ ២៖** លើកទឹកចិត្តយុវជនឱ្យមានគំនិតផ្តួចផ្តើម គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាព។

**គោលដៅ ៣៖** លើកកម្ពស់យេនឌ័រប្រកបដោយសមធម៌ និងសមភាពដល់យុវជនទាំងពីរភេទពិសេសផ្តល់ឱកាសនិងសិទ្ធិអំណាចដល់ស្ត្រី។

**គោលដៅ ៤៖** អភិវឌ្ឍយុវជនឱ្យមានកាយសម្បទា ចំណេះដឹង ចំណេះធ្វើ សីលធម៌រស់នៅល្អ។ល។

**គោលដៅ ៥៖** បង្កឱកាសឱ្យយុវជនបានចូលរួមបញ្ចេញមតិ ទស្សនៈ និងធ្វើសេចក្តីសម្រេចចិត្តនានាក្នុងការអភិវឌ្ឍសហគមន៍ និងសង្គមជាតិ។

**គោលដៅ ៦៖** ប្រមូលផ្តុំកម្លាំងគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល សហគមន៍មាតាបិតាឬអ្នកអាណាព្យាបាល ដើម្បីអភិវឌ្ឍយុវជនកម្ពុជា។

*រាជរដ្ឋាភិបាលកម្ពុជា គោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍យុវជន ឆ្នាំ២០១១។*

# ចំណេះដឹងអំពីគោលនយោបាយ និង យុទ្ធសាស្ត្រពាក់ព័ន្ធនឹងយុវជន

**ការយល់ដឹងរបស់យុវជន ជាទូទៅអំពីយុទ្ធសាស្ត្រអភិវឌ្ឍន៍សំខាន់ៗរបស់រដ្ឋាភិបាល និងជាពិសេសអំពីគោលនយោបាយយុវជន មានកម្រិតទាប។**

- ៩០% នៃអ្នកដែលត្រូវបានស្ទង់មតិ បាននិយាយថា ពួកគេមិនធ្លាប់បានឮអំពីយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ នោះទេ។ ចំនួនស្ទើរតែដូចគ្នា (៨៩%) បាននិយាយថា ពួកគេមិនធ្លាប់ឮអំពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា។ ៨៤% បាននិយាយថាពួកគេមិនបានដឹងអំពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឡើយ។
- មានតែ ១៥% ប៉ុណ្ណោះ ដែលបាននិយាយថា ពួកគេធ្លាប់បានឮអំពីគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍យុវជន ឆ្នាំ ២០១១។ ប៉ុន្តែនៅពេលសួរបន្ថែមទៀត ក្នុងចំណោមពួកគេ មានតែ ៥% ប៉ុណ្ណោះ ដែលផ្តល់ចម្លើយត្រឹមត្រូវ ទាក់ទងទៅនឹងបញ្ហាសំខាន់ៗ ដែលឯកសារគោលនយោបាយនេះគ្របដណ្តប់។
- ដូចគ្នាដែរ មានតែ ១៥% ប៉ុណ្ណោះដែលបាននិយាយថា ពួកគេបានដឹងពីវត្តមាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍យុវជន។ ការវិភាគបន្ថែមបានបង្ហាញថា អ្នកដែលធ្លាប់បានឮអំពីគោលនយោបាយសំខាន់ៗពាក់ព័ន្ធនឹងយុវជន ឬក្រុមប្រឹក្សាយុវជន ភាគច្រើនគឺជាអ្នកដែលរស់នៅទីប្រជុំជន មានការអប់រំខ្ពស់ មានការងារធ្វើ និងមានចំណូលច្រើនក្នុងគ្រួសារ។

**អនុសាសន៍៖**

- រដ្ឋាភិបាលគួរតែរៀបចំផែនការរយៈពេលខ្លី និងរយៈពេលវែង ដើម្បីបង្កើនការយល់ដឹងរបស់យុវជន អំពីគោលនយោបាយ និងយុទ្ធសាស្ត្រសំខាន់ៗរបស់រដ្ឋាភិបាល ដោយរួមបញ្ចូលទាំងវិធីសាស្ត្រ និងគំនិតផ្តួចផ្តើមនានាផងដែរ ដើម្បីបង្កើនចំណេះដឹងពលរដ្ឋវ័យក្មេងដែលមានភេទ និងកត្តាសេដ្ឋកិច្ចសង្គមខុសៗគ្នា។
- អង្គការសង្គមស៊ីវិល ស្ថាប័នអប់រំ និងប្រព័ន្ធផ្សព្វផ្សាយ គួរតែបង្កើតភាពជាដៃគូ ដើម្បីបង្កើនចំណាប់អារម្មណ៍ និងចំណេះដឹងរបស់យុវជនអំពីគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលពាក់ព័ន្ធនឹងយុវជន ព្រមទាំងដំណើរការ និងលទ្ធផលនៃការអនុវត្តគោលនយោបាយទាំងនេះផងដែរ។
- ភាគីដែលធ្វើការពាក់ព័ន្ធនឹងយុវជន ជាពិសេសរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល គួរតែបង្កើនកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីលើកកម្ពស់ការចូលរួមដ៏មានអត្ថន័យរបស់យុវជននៅគ្រប់ដំណាក់កាលនៃដំណើរការគោលនយោបាយ (ឧទាហរណ៍៖ ការកំណត់បញ្ហា ការអនុវត្ត ការត្រួតពិនិត្យ និងវាយតម្លៃ) ដើម្បីបង្កើនតម្លាភាព និងគណនេយ្យភាពរបស់រដ្ឋាភិបាល ព្រមទាំងភាពជាម្ចាស់ខ្លួនឯងរបស់យុវជនផងដែរ។

## តើអ្នកធ្លាប់ឮអំពីឯកសារខាងក្រោមនេះដែរឬទេ?




## តើអ្នកធ្លាប់ឮអំពី “ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន” ដែរឬទេ?




## យុវជនដែលនិយាយថាពួកគេធ្លាប់ឮអំពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍យុវជន៖វិភាគតាមតំបន់ ការអប់រំ និងចំណូលគ្រួសារ




## យុវជនដែលនិយាយថាពួកគេធ្លាប់ឮអំពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា៖ វិភាគតាមតំបន់ ការអប់រំ និងចំណូលគ្រួសារ



# សុខភាព

### ការចំណាយលើសុខភាពបានកើនឡើងសម្រាប់យុវជនកម្ពុជាមួយចំនួន។

- ម្នាក់ក្នុងចំណោមយុវជនបួននាក់ (២៤%) បានរាយការណ៍ថា ប្រាក់ដែលពួកគេចំណាយសម្រាប់ការថែទាំសុខភាពរបស់ពួកគេកាលពីឆ្នាំមុន បានកើនឡើងបន្តិចបន្តួច ឬច្រើន។ នៅពេលធ្វើការវិភាគបន្ថែមតាមកត្តាភេទ យុវជនជាស្ត្រី (៣០%) ច្រើនជាងយុវជនជាបុរស (១៨%) ដែលបានរាយការណ៍ថាប្រាក់ដែលពួកគេចំណាយសម្រាប់ការថែទាំសុខភាពរបស់ពួកគេបានកើនឡើងក្នុងមួយឆ្នាំចុងក្រោយ។

### យុវជនមួយចំនួនតូចពុំមានលទ្ធភាពចំណាយលើថ្លៃសេវាថែទាំសុខភាពផ្ទាល់ខ្លួនរបស់ពួកគេនោះទេ។

- អ្នកចូលរួមក្នុងការស្ទង់មតិ ១៤% បានរាយការណ៍ថា ពួកគេចាំបាច់ត្រូវពន្យារពេលទៅព្យាបាលជំងឺកាលពីឆ្នាំមុន ដោយសារពួកគេពុំមានលទ្ធភាពចំណាយលើថ្លៃព្យាបាល។ ការវិភាគបន្ថែមបង្ហាញថាស្ត្រី អ្នករស់នៅជនបទ និងអ្នកមានចំណូលគ្រួសារទាប ឧស្សាហ៍ពន្យារពេលទៅទទួលការព្យាបាលជាងបុរស អ្នករស់នៅទីប្រជុំជន និងអ្នកដែលមានចំណូលគ្រួសារខ្ពស់។

### យុវជនមួយចំនួនតូចបានជួបប្រទះទម្រង់មួយចំនួននៃការរើសអើង និងការបៀតបៀននៅខណៈពេលទៅទទួលសេវាថែទាំសុខភាពរបស់រដ្ឋ។

- អ្នកឆ្លើយតបសម្ភាស ៦% ដែលបានទទួលសេវាថែទាំសុខភាពរបស់រដ្ឋក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ បានរាយការណ៍ថា បានជួបប្រទះការរើសអើង ដោយសារអត្តសញ្ញាណយេនឌ័ររបស់ពួកគេ (ស្ត្រី LGBTIG+) ឬភាពងាយរងគ្រោះរបស់ពួកគេ (ភាពក្រីក្រ ពិការភាព ឬជាតិពន្ធុ)។ ភាគរយស្រដៀងគ្នានេះដែរបាននិយាយថា ពួកគេបានជួបប្រទះការបៀតបៀនផ្លូវភេទ ដោយសារអត្តសញ្ញាណយេនឌ័រ និងភាពងាយរងគ្រោះរបស់ពួកគេ។

### យុវជនក្នុងចំនួនច្រើនគួរសមយល់ឃើញថា កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការពង្រឹងការផ្តល់សេវាសុខាភិបាល ដល់យុវជន នៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ។

- យុវជនស្ទើរតែ៤នាក់ក្នុងចំណោម១០នាក់ (៣៨%)ដែលចូលរួមការស្ទង់មតិ យល់ឃើញថា គោលដៅពង្រឹងការផ្តល់សេវាសុខាភិបាលដល់យុវជន ដែលបានកំណត់នៅក្នុងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន ឆ្នាំ២០១១ សម្រេចបានតែមួយផ្នែកប៉ុណ្ណោះ ឬបានតិចតួចបំផុត។

### សេវាកម្មមិនល្អ ត្រូវបានមើលឃើញថាជាបញ្ហាប្រឈមដ៏ធំបំផុត នៅក្នុងសេវាសុខភាពរបស់រដ្ឋ បន្ទាប់មកគឺកង្វះបរិក្ខារ និងធនធានមនុស្ស ហើយនិងការចំណាយខ្ពស់។

- អ្នកឆ្លើយតបសម្ភាស ៣០% បានឆ្លើយថា សេវាកម្មមិនល្អ – រួមទាំង អំពើពុករលួយ និងការផ្តល់សេវាមិនស្មើភាព – គឺជាបញ្ហាធំបំផុតនៅក្នុងសេវាសុខភាពសាធារណៈនៅក្នុងប្រទេស។ ខណៈ២៣% បានគិតថាកង្វះបរិក្ខារ និងធនធានមនុស្ស ហើយ ៩% បាននិយាយថាការចំណាយខ្ពស់ គឺជាបញ្ហាធំបំផុត។

**អនុសាសន៍៖**

- រដ្ឋាភិបាលគួរតែគៀងគរធនធានបន្ថែមសម្រាប់ការថែទាំសុខភាព តាមរយៈការបែងចែកថវិកា និងការកែលម្អប្រសិទ្ធភាពចំណាយលើវិស័យសុខាភិបាល។ ទន្ទឹមនឹងនេះ រដ្ឋាភិបាលគួរតែពង្រឹងប្រព័ន្ធហិរញ្ញវត្ថុឱ្យកាន់តែមានតម្លាភាព និងគណនេយ្យភាព។
- បង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីធានាថាសេវាថែទាំសុខភាពមានការឆ្លើយតប ស្វែងរកបានដោយងាយស្រួល និងតម្លៃសមរម្យសម្រាប់មនុស្សគ្រប់រូប រួមទាំង យុវជន និងជនងាយរងគ្រោះផងដែរ។ អ្នកជំនាញផ្នែកថែទាំសុខភាពគួរតែមានកាតព្វកិច្ចចូលរួមវគ្គសិក្សាស្តីពីក្រមប្រតិបត្តិ និងក្រមសីលធម៌ ព្រមទាំងការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជាមួយអ្នកជំងឺផងដែរ។
- ពង្រឹងសមត្ថភាពនៃសេវាថែទាំសុខភាព ប្រព័ន្ធ និងហេដ្ឋារចនាសម្ព័ន្ធ និងធ្វើជាដៃគូជាមួយវិស័យឯកជនក្នុងការកសាងប្រព័ន្ធថែទាំសុខភាព ហេដ្ឋារចនាសម្ព័ន្ធ

និងសេវាកម្ម ដែលមានគុណភាពខ្ពស់ និងមានតម្លៃកាន់តែសមរម្យ នៅក្នុងប្រទេសកម្ពុជា។

- អនុម័ត និងអនុវត្តធម្មនុញ្ញរបស់ពលរដ្ឋដែលគូសបញ្ជាក់អំពីការប្តេជ្ញាចិត្តចំពោះការមិនរើសអើង ឬការផ្តល់ដោយស្មើភាពនូវគ្រប់សេវាសាធារណៈទាំងអស់នៅក្នុងប្រទេស។ ឧទាហរណ៍ ឯកសារនេះអាចផ្តោតជាពិសេសលើការមិនរើសអើងលើពិការភាព ជាតិសាសន៍ ជាតិពន្ធុ ភេទឬអាយុ ។ល។

## សុខភាព

១ ក្នុង ចំណោម ៤នាក់៖ និយាយថាការចំណាយលើសុខភាពរបស់ពួកគេក្នុងមួយឆ្នាំចុងក្រោយមានការកើនឡើង

ភាគរយអ្នកដែលបាននិយាយថាការចំណាយលើសេវាសុខភាពរបស់ពួកគេមានការកើនឡើងក្នុងរយៈពេលមួយឆ្នាំចុងក្រោយផ្អែកលើកត្តាភេទ

៣០% ១៨%

១៤% | ពន្យារពេលទៅរកសេវាសុខភាពកាលពីឆ្នាំមុន ដោយសារពួកគេពុំមានលទ្ធភាពចំណាយលើថ្លៃព្យាបាល។

### ភាគរយយុវជនដែលបានពន្យារពេលទៅរកសេវាសុខភាព ដោយសារតែពួកគេពុំមានលទ្ធភាពចំណាយលើថ្លៃព្យាបាល ដោយបែងចែកតាមកត្តាភេទ តំបន់ និងចំណូលក្នុងគ្រួសារ




### តាមការយល់ឃើញរបស់អ្នក តើបញ្ហាធំបំផុតនៅក្នុងវិស័យសុខាភិបាលនៅកម្ពុជាគឺជាអ្វី?

៣០% សេវាកម្មមិនល្អ – រួមទាំង អំពើពុករលួយ និងការផ្តល់សេវាមិនស្មើភាព

២៣% កង្វះបរិក្ខារ និងធនធានមនុស្ស

៩% ការចំណាយខ្ពស់

### គោលដៅសំខាន់មួយនៃគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍យុវជន គឺដើម្បីបង្កើនការផ្តល់សេវាសុខភាពសម្រាប់យុវជន។ តើអ្នកគិតថាគោលដៅនេះសម្រេចបានកម្រិតណាហើយ?



# ការអប់រំ

**យុវជនមួយចំនួនតូចមានអារម្មណ៍ថា ពួកគេត្រូវបានរើសអើង ឬបៀតបៀននៅក្នុងសាលារៀនដោយផ្អែកលើអត្តសញ្ញាណយេនឌ័រ ឬភាពងាយរងគ្រោះរបស់ពួកគេ។**

- យុវជនជិតម្នាក់ក្នុងចំណោមដប់នាក់ (៩%) បានរាយការណ៍ថា ពួកគេត្រូវបានរើសអើងដោយសារអត្តសញ្ញាណយេនឌ័រ ឬភាពងាយរងគ្រោះរបស់ពួកគេ ក្នុងអំឡុងពេលសិក្សានៅសាលារៀនរបស់ពួកគេ។ ភាគរយយុវជនស្រដៀងគ្នាបាននិយាយថា ពួកគេត្រូវបានបៀតបៀននៅក្នុងសាលារៀនដោយសារអត្តសញ្ញាណយេនឌ័រ ឬភាពងាយរងគ្រោះរបស់ពួកគេ។

**យុវជនកម្ពុជាទទួលស្គាល់សារសំខាន់នៃការសិក្សាថ្នាក់ឧត្តម និងវគ្គបណ្តុះបណ្តាលនានាបន្ទាប់ពីកម្រិតវិទ្យាល័យ បើទោះបីជាពួកគេក៏គិតផងដែរថាការសិក្សាទាំងនោះត្រូវចំណាយខ្ពស់។**

- ពាក់កណ្តាលនៃអ្នកឆ្លើយតបសម្ភាស (៥០%) បានយល់ឃើញថា សញ្ញាបត្របណ្តុះបណ្តាលវិជ្ជាជីវៈ ឬសញ្ញាបត្រកម្រិតសាកលវិទ្យាល័យ គឺចាំបាច់ដើម្បីទទួលជោគជ័យនៅក្នុងសង្គម។ ប៉ុន្តែ ៧៤% បានយល់ស្រប ឬយល់ស្របទាំងស្រុង ចំពោះអំណះអំណាងដែលលើកឡើងថា "ការអប់រំដែលខ្ញុំចង់បាន គឺលើសពីលទ្ធភាពហិរញ្ញវត្ថុរបស់ខ្ញុំ"។

**យុវជនមានទស្សនៈផ្សេងគ្នាចំពោះការអនុវត្តគោលនយោបាយស្តីពីការអប់រំយុវជនរបស់រដ្ឋាភិបាល។**

- យុវជន ៤៤% បានគិតថា គោលដៅនៃការផ្តល់ការអប់រំប្រកបដោយគុណភាពដល់យុវជន ដូចមានចែងនៅក្នុងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន ឆ្នាំ២០១១ សម្រេចបានទាំងស្រុង ឬមួយភាគធំ។ ទោះបីជាយ៉ាងនេះក្តី ៣២% បានជឿថា គោលដៅនោះសម្រេចបានតែមួយផ្នែកប៉ុណ្ណោះ ឬតិចតួចបំផុត ដែលបង្ហាញថា រដ្ឋាភិបាលមិនទាន់អនុវត្តបានគ្រប់គ្រាន់នៅឡើយនៅក្នុងការលើកកម្ពស់ការអប់រំប្រកបដោយគុណភាពសម្រាប់យុវជន។

**យោងតាមយុវជន លទ្ធភាពទទួលបានការសិក្សា និងបរិយាកាសសិក្សា ការចំណាយ និងគុណភាពនៃការបង្រៀនជាបញ្ហាធំបំផុតទាំងបី នៅក្នុងប្រព័ន្ធអប់រំសាធារណៈ។**

- ២៨% នៃអ្នកឆ្លើយតបសម្ភាសបានចាត់ទុក លទ្ធភាពទទួលបានការសិក្សា និងបរិយាកាសសិក្សា ជាបញ្ហាធំបំផុតនៅក្នុងប្រព័ន្ធអប់រំសាធារណៈ។ ប្រហែល ២២% បានលើកឡើងថា បញ្ហាធំបំផុត គឺការចំណាយច្រើន ខណៈដែល ១៨% គិតថា ជាគុណភាពនៃការបង្រៀន។

**អនុសាសន៍៖**

- រដ្ឋាភិបាលគួរបង្កើនថវិកាបន្ថែមទៀតសម្រាប់វិស័យអប់រំ ទន្ទឹមនឹងនេះធានាថាការចំណាយថវិកាទាំងនោះនឹងត្រូវធ្វើឡើងប្រកបដោយប្រសិទ្ធភាព។
- បង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីពង្រឹងភាពអាចស្វែងរកបាន និងគុណភាពនៃការអប់រំ ព្រមទាំងលទ្ធភាពទទួលបានឱកាសសិក្សាប្រកបដោយគុណភាពខ្ពស់ និងសមធម៌សម្រាប់យុវជន។
- រដ្ឋាភិបាលគួរតែរួមបញ្ចូលភាគីពាក់ព័ន្ធក្នុងវិស័យអប់រំទាំងអស់ (រួមទាំងយុវជន និងវិស័យឯកជន) នៅគ្រប់ដំណាក់កាលនៃដំណើរការគោលនយោបាយអប់រំ ចាប់ពីការរៀបចំផែនការរហូតដល់ការអនុវត្ត។
- អ្នកបង្កើតគោលនយោបាយ និងស្ថាប័នអប់រំ ទាំងសាធារណៈ និងឯកជន គួរតែស្វែងរកមធ្យោបាយបន្ថែមដើម្បីធានាថា ការអប់រំថ្នាក់ឧត្តមសិក្សា និងការបណ្តុះបណ្តាលវិជ្ជាជីវៈ គឺសមស្របនឹងលទ្ធភាពហិរញ្ញវត្ថុរបស់យុវជនកម្ពុជា ដែលមានបំណងចង់បន្តគោលដៅសិក្សារបស់ពួកគេ។
- ធានាថា ការអប់រំមានសម្រាប់កុមារគ្រប់រូប ប្រកបដោយបរិយាប័ន្ន ដែលឆ្លើយតបនឹងតម្រូវការអប់រំរបស់កុមារ និងយុវជន។
- គៀងគរធនធាន និងកិច្ចខិតខំប្រឹងប្រែង ដើម្បីកែលម្អបរិយាកាសសិក្សា ហេដ្ឋារចនាសម្ព័ន្ធ និងឧបករណ៍សិក្សារបស់សាលារៀន រួមទាំងការអនុម័ត និងការតភ្ជាប់បច្ចេកវិទ្យាព័ត៌មាន(ICT)។
- ពន្លឿនកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនសមត្ថភាពបុគ្គល ជាពិសេសគ្រូបង្រៀន និងស្ថាប័នដែលទទួលបន្ទុកលើការអប់រំកុមារ។

# ការអប់រំ

**៩%** បានរាយការណ៍ថាត្រូវបានគេ **រើសអើង**នៅក្នុងសាលារៀន ដោយសារតែអត្តសញ្ញាណយេនឌ័រ ឬភាពងាយរងគ្រោះរបស់ពួកគេ

**១០%** បានរាយការណ៍ថាត្រូវបានគេ **បៀតបៀន**នៅក្នុងសាលារៀន ដោយសារតែអត្តសញ្ញាណយេនឌ័រ ឬភាពងាយរងគ្រោះរបស់ពួកគេ

## តើអ្នកគិតថាមនុស្សម្នាក់ត្រូវមានការអប់រំកម្រិតណាទើបអាចទទួលជោគជ័យនៅក្នុងសង្គមយើង?

| | |
|---|---|
| ត្រឹមចេះអាន និងសរសេរអក្សរ | ៨% |
| ទាបជាងវិទ្យាល័យ | ១% |
| ចប់វិទ្យាល័យ | ៣៧% |
| សញ្ញាបត្របណ្តុះបណ្តាលវិជ្ជាជីវៈ | ៩% |
| កម្រិតសាកលវិទ្យាល័យ | ៤១% |
| មិនដឹង/បដិសេធឆ្លើយ | ៤% |

## តើអ្នកយល់ស្របកម្រិតណាចំពោះប្រយោគដែលថា "ការអប់រំដែលខ្ញុំចង់បានគឺវាហួសពីលទ្ធភាពថវិការបស់ខ្ញុំ"?

**១៥%** មិនយល់ស្រប

**១០%** យល់ស្របផង មិនយល់ស្របផង

**៧៤%** យល់ស្រប

## តាមការយល់ឃើញរបស់អ្នក តើបញ្ហាធំបំផុតនៅក្នុងប្រព័ន្ធអប់រំរដ្ឋនៅកម្ពុជាគឺជាអ្វី?

**២៨%** លទ្ធភាពទទួលបាន និងបរិយាកាសសិក្សា

**២២%** ការចំណាយខ្ពស់

**១៨%** គុណភាពនៃការបង្រៀន

## គោលដៅសំខាន់មួយនៃគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍យុវជនគឺផ្តល់ឱកាសឱ្យយុវជនទទួលបានការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានគុណភាព។ តើអ្នកគិតថាគោលដៅនេះសម្រេចបានជោគជ័យកម្រិតណាហើយ?

| | |
|---|---|
| សម្រេចបានពេញលេញ | ៥% |
| សម្រេចបានភាគច្រើន | ៣៩% |
| សម្រេចបានខ្លះៗ | ២៦% |
| សម្រេចបានតិចតួច | ៧% |
| មិនសម្រេចបានទាល់តែសោះ | ១% |
| មិនដឹង/បដិសេធឆ្លើយ | ២២% |

# ការងារ

## ការអប់រំ និងជំនាញពាក់ព័ន្ធត្រូវបានយុវជនកម្ពុជាមើលឃើញថា ជាគន្លឹះក្នុងការធានាបាននូវការងារនៅក្នុងវិស័យសាធារណៈ បន្ទាប់មកគឺ ទំនាក់ទំនងផ្ទាល់ខ្លួន និងប្រាក់ ហើយនិងបទពិសោធន៍ការងារ។

- យុវជន ៧៤% បាននិយាយថា ការដែលមានការអប់រំនិងជំនាញត្រឹមត្រូវ ធ្វើឱ្យមានភាពងាយស្រួលក្នុងការស្វែងរកការងារនៅក្នុងវិស័យសាធារណៈ។ប្រហែលម្នាក់ក្នុងចំណោមដប់នាក់ (១១%) បាននិយាយថា គឺទំនាក់ទំនងផ្ទាល់ខ្លួននិងប្រាក់ ហើយ ៧% បានលើកឡើងអំពីបទពិសោធន៍ការងារ។

## យុវជនមួយចំនួនតូចដែលមានការងារធ្វើ បានជួបប្រទះការរើសអើង ឬការបៀតបៀននៅកន្លែងធ្វើការដោយសារអត្តសញ្ញាណយេនឌ័រ ឬភាពងាយរងគ្រោះរបស់ពួកគេ។

- ក្នុងចំណោមយុវជនដែលមានការងារធ្វើ ដែលបានចូលរួមក្នុងការស្ទង់មតិនេះ យុវជនជិតម្នាក់ក្នុងចំណោមដប់នាក់ (៩%) បាននិយាយថា ពួកគេមានអារម្មណ៍ថាត្រូវបានគេរើសអើងនៅកន្លែងធ្វើការ ដោយសារអត្តសញ្ញាណយេនឌ័រ ឬភាពងាយរងគ្រោះរបស់ពួកគេ។ ទន្ទឹមនឹងនេះ ៧% បានរាយការណ៍ថា បានរងការបៀតបៀន ដោយសារលក្ខណៈយេនឌ័រ ឬភាពងាយរងគ្រោះរបស់ពួកគេ។

## យុវជនជាច្រើននាក់បានជឿថា កន្លែងការងារនៅប្រទេសកម្ពុជាមិនបានផ្តល់ឱកាសការងារគ្រប់គ្រាន់ដល់យុវជនមានពិការភាពនោះទេ។

- ពាក់កណ្តាលនៃយុវជន (៥០%) បានជឿថា កន្លែងការងារនៅប្រទេសកម្ពុជាមិនបានផ្តល់ឱកាសការងារគ្រប់គ្រាន់ដល់យុវជនមានពិការភាពនោះទេ។

## កង្វះលទ្ធភាពទទួលបានព័ត៌មានអំពីការងារ គឺជាបញ្ហាប្រឈមមួយសម្រាប់យុវជនកម្ពុជា

- អ្នកឆ្លើយតបសម្ភាស ៧៣% បានយល់ស្រប ឬយល់ស្របទាំងស្រុងចំពោះអំណះអំណាងដែលលើកឡើងថា "ខ្ញុំពុំបានទទួលព័ត៌មានអំពីការងារគ្រប់គ្រាន់នោះទេ"។

## យុវជនភាគច្រើនមានការព្រួយបារម្ភថា ពួកគេមានសមត្ថភាពមិនគ្រប់គ្រាន់ដើម្បីទទួលបានការងារណាមួយ។

- ៨៤% បានយល់ស្រប ឬយល់ស្របទាំងស្រុងចំពោះអំណះអំណាងដែលលើកឡើងថា "ខ្ញុំបារម្ភថាខ្ញុំខ្វះជំនាញដែលចាំបាច់ដើម្បីទទួលបានការងារណាមួយ"។

## យុវជនភាគច្រើនបានជឿថា ឧបសគ្គធំបំផុតសម្រាប់មនុស្សជំនាន់ពួកគេ គឺការស្វែងរកការងារដែលមានប្រាក់បៀវត្សរ៍ខ្ពស់។

- ៨៦% បានយល់ស្របនឹងការអះអាងដែលថា ឧបសគ្គធំបំផុតសម្រាប់មនុស្សជំនាន់ពួកគេ គឺការស្វែងរកការងារដែលមានប្រាក់បៀវត្សរ៍ខ្ពស់។

## យុវជនជាច្រើននាក់មានអារម្មណ៍ថា មានកិច្ចការជាច្រើនទៀតដែលរដ្ឋាភិបាលអាចធ្វើបានដើម្បីលើកកម្ពស់ការងាររបស់យុវជននៅក្នុងប្រទេសកម្ពុជា។

- នៅពេលមកដល់ចំណុចនេះ ចម្លើយមានភាពខុសគ្នាយ៉ាងខ្លាំង៖ ខណៈពេលដែលអ្នកឆ្លើយតប ៣៧% បានគិតថាគោលដៅរបស់គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនក្នុងការលើកកម្ពស់ការងាររបស់យុវជន សម្រេចបានទាំងស្រុង ឬមួយភាគធំ អ្នកឆ្លើយតបដែលមានភាគរយស្ទើរតែដូចគ្នា (៣៨%) បាននិយាយថា គោលដៅនោះសម្រេចបានមួយផ្នែក ឬតិចតួចបំផុត។

## បញ្ហាធំបំផុតទាំងបីនៅក្នុងវិស័យការងារ យោងតាមយុវជនដែលត្រូវបានស្ទង់មតិ រួមមាន ប្រាក់បៀវត្សរ៍ទាប កង្វះខាតនិងភាពមិនស៊ីគ្នានៃជំនាញ និងឱកាសការងារមិនគ្រប់គ្រាន់។

- អ្នកដែលត្រូវបានស្ទង់មតិ ៣៨% បានកំណត់ថា ប្រាក់បៀវត្សរ៍ទាប គឺជាបញ្ហាធំបំផុតនៅក្នុងវិស័យការងារ។ ម្នាក់ក្នុងចំណោមបួននាក់ (២៥%) បានគិតថាជាកង្វះខាត និងភាពមិនត្រូវគ្នានៃជំនាញ។ ដោយឡែក ប្រហែល ១៧% បានលើកឡើងថាជា កង្វះខាតឱកាសការងារ។

**អនុសាសន៍៖**

លទ្ធផលនៃការស្ទង់មតិខាងលើបង្ហាញថាទាំងវិធានការផ្នែកផ្គត់ផ្គង់ និងវិធានការផ្នែកតម្រូវការគឺមានភាពចាំបាច់ដើម្បីលើកកម្ពស់ការងាររបស់យុវជននៅក្នុងប្រទេសកម្ពុជា៖

**វិធានការផ្នែកផ្គត់ផ្គង់៖**

- ផ្តល់អាទិភាព និងពង្រីកការវិនិយោគទៅលើការអភិវឌ្ឍជំនាញ ការអប់រំអំពីការងារ និងការណែនាំសម្រាប់យុវជនទាំងនៅក្នុងការអប់រំពេញម៉ោងនិងក្រៅម៉ោង។
- ពង្រឹងលទ្ធភាពទទួលបានការងារសម្រាប់យុវជន ជាពិសេសអ្នកដែលមកពីក្រុមជួបការលំបាក តាមរយៈការបង្កើនកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយការបោះបង់ការសិក្សា និងកែលម្អទំនាក់ទំនងរវាងសាលារៀន ការបណ្តុះបណ្តាល និងទីផ្សារការងារ។
- បង្កើនលទ្ធភាពទទួលបានការអប់រំដែលមានគុណភាពខ្ពស់របស់យុវជន ដែលផ្តល់ជូនពួកគេនូវជំនាញគ្រឹះដើម្បីទទួលបានការងារ បន្ថែមពីលើចំណេះដឹងផ្នែកបច្ចេកទេស និងវិជ្ជាជីវៈ។
- រៀបចំប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលដែលធ្វើឱ្យយុវជនអាចសម្របខ្លួនទៅនឹងការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃលក្ខណៈការងារ ដែលបណ្តាលមកពីបច្ចេកវិទ្យា និងប្រាជ្ញាសប្បនិម្មិត។
- ដោះស្រាយឧបសគ្គផ្នែកហិរញ្ញវត្ថុដែលរារាំងយុវជនពីឱកាសជ្រើសរើស និង/ឬបញ្ចប់ការអប់រំ និងការបណ្តុះបណ្តាល ឧទាហរណ៍ តាមរយៈការដាក់ចេញនូវយន្តការគាំទ្រជួយសិស្សនិស្សិតវ័យក្មេងក្នុងការទប់ទល់នឹងការលំបាកផ្នែកហិរញ្ញវត្ថុ។
- រៀបចំប្រព័ន្ធ ដែលជួយដល់យុវជនក្នុងការទទួលបានព័ត៌មានអំពីទីផ្សារការងារ និងជម្រើសការងារកាត់បន្ថយចំណាយលើការស្វែងរកការងារ និងផ្តល់ជំនួយក្នុងការផ្គូផ្គងការងារឱ្យត្រូវនឹងជំនាញ។
- ពង្រឹងការចូលរួមពីវិស័យឯកជនក្នុងការអភិវឌ្ឍជំនាញ និងការងារ ហើយអនុវត្តកម្មវិធីនានាដែលចូលរួមយ៉ាងសកម្មនៅក្នុងទីផ្សារការងារ និងជាពិសេសផ្តោតលើមនុស្សវ័យជំទង់ដែលមានហានិភ័យ។
- ធ្វើឱ្យកាន់តែប្រសើរនូវលទ្ធភាពទទួលបានការអប់រំ ការអភិវឌ្ឍជំនាញ និងការសិក្សាពេញមួយជីវិតសម្រាប់យុវជនមានពិការភាព និងពង្រឹងឱកាសការងារសមរម្យទាំងនៅក្នុងវិស័យសាធារណៈ និងវិស័យឯកជនសម្រាប់មនុស្សក្រុមនេះ។
- ពង្រឹងស្តង់ដារ និងការអនុវត្តការអប់រំនៅគ្រប់កម្រិតធានាបាននូវការផ្គូផ្គងការសិក្សា និងការបណ្តុះបណ្តាលជាមួយតម្រូវការនៃទីផ្សារការងារដែលមានស្រាប់ និងដែលបានព្យាករណ៍។ រដ្ឋាភិបាល វិស័យឯកជន និងស្ថាប័នអប់រំគួរតែធ្វើការឱ្យកាន់តែជិតស្និទ្ធបន្ថែមទៀតដើម្បីបង្កើនភាពពាក់ព័ន្ធនៃការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ(TVET)និងការអប់រំកម្រិតឧត្តមសិក្សា។

**វិធានការផ្នែកតម្រូវការ៖**

- រដ្ឋាភិបាលគួរតែបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការនាំមកនូវការវិនិយោគដើម្បីពង្រីកសេដ្ឋកិច្ច និងបង្កើតការងារបន្ថែមទៀត ជាពិសេសការងារដែលប្រើបច្ចេកវិទ្យា និងជំនាញកម្រិតខ្ពស់។ កិច្ចខិតខំប្រឹងប្រែងទាំងនោះក៏ទាមទារឱ្យមានការអភិវឌ្ឍ និងផ្តល់គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច សារពើពន្ធ និងឧស្សាហកម្មដែលសង្កត់ធ្ងន់លើកំណើនការងារជំនាញ និងគុណភាពការងារយ៉ាងខ្លាំងផងដែរ។
- លើកកម្ពស់ឱកាសទទួលបានការងារស្មើៗគ្នាក្នុងវិស័យសាធារណៈ សម្រាប់យុវជនដោយធានាថា ការជ្រើសរើស ការរក្សាទុក និងការដំឡើងតំណែងមន្ត្រីសាធារណៈ គឺផ្អែកលើគុណសម្បត្តិ ការប្រកួតប្រជែងដោយយុត្តិធម៌ និងបើកចំហ និងគ្មានការរើសអើង។ នេះតម្រូវឱ្យមានការអនុម័ត និងអនុវត្តប្រព័ន្ធជ្រើសរើសបុគ្គលិកដែលមានភាពច្បាស់លាស់ បើកចំហ និងមានតម្លាភាព ដែលអាចឱ្យបេក្ខជនដែលសាកសមបំផុតដែលមានជំនាញជាក់លាក់ល្អបំផុតសម្រាប់ការងារ។

# ការងារ

**ដើម្បីងាយទទួលបានការងារធ្វើមួយ តើយើងត្រូវមានអ្វីសំខាន់ជាងគេ?**

**១១%** ទំនាក់ទំនងផ្ទាល់ខ្លួន និងប្រាក់

**៧៤%** ការអប់រំនិងជំនាញពាក់ព័ន្ធ

**៧%** បទពិសោធន៍ការងារ

## បទពិសោធន៍ជួបប្រទះការរើសអើង និងការបៀតបៀនក្នុងចំណោមយុវជនដែលធ្វើការ

**៩%** បានរាយការណ៍ថាត្រូវបានគេរើសអើងនៅកន្លែងការងារ ដោយសារតែអត្តសញ្ញាណយេនឌ័រ ឬភាពងាយរងគ្រោះរបស់ពួកគេ

**៧%** បានរាយការណ៍ថាត្រូវបានគេបៀតបៀននៅកន្លែងការងារ ដោយសារតែអត្តសញ្ញាណយេនឌ័រ ឬភាពងាយរងគ្រោះរបស់ពួកគេ

**៧៣%** បាននិយាយថាពួកគេពុំបានទទួលព័ត៌មានគ្រប់គ្រាន់អំពីការងារ

**៨៤%** បារម្ភថាពួកគេខ្វះជំនាញដែលចាំបាច់ដើម្បីទទួលបានការងារណាមួយ

**៨៦%** និយាយថាបញ្ហាប្រឈមធំបំផុតសម្រាប់ជំនាន់របស់ពួកគេ គឺការទទួលបានការងារមានប្រាក់ខែល្អ

## ១ ក្នុងចំណោម២នាក់

គិតថាកន្លែងការងារនៅកម្ពុជាមិនបានផ្តល់ឱកាសការងារគ្រប់គ្រាន់សម្រាប់យុវជនមានពិការភាព។

## តាមការយល់ឃើញរបស់អ្នក តើបញ្ហាធំបំផុតនៅក្នុងវិស័យការងារនៅកម្ពុជាគឺជាអ្វី?

ប្រាក់បៀវត្សរ៍ទាប **៣៨%**

កង្វះខាត និងភាពមិនស៊ីគ្នានៃជំនាញ **២៥%**

កង្វះឱកាសការងារ **១៧%**

## គោលដៅសំខាន់មួយនៃគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍យុវជនគឺបង្កើនការងារសម្រាប់យុវជន។ តើអ្នកគិតថាគោលដៅនេះសម្រេចបានជោគជ័យកម្រិតណាហើយ?

| | |
|---|---|
| សម្រេចបានពេញលេញ | ៣% |
| សម្រេចបានភាគច្រើន | ៣៤% |
| សម្រេចបានខ្លះៗ | ២៩% |
| សម្រេចបានតិចតួច | ៩% |
| មិនសម្រេចបានទាល់តែសោះ | ១% |
| មិនដឹង/បដិសេធឆ្លើយ | ២៤% |

# ការចូលរួមរបស់ពលរដ្ឋ និងការចូលរួមផ្នែកនយោបាយ

## ចំណេះដឹងរបស់យុវជនអំពីសិទ្ធិចូលរួមនៅក្នុងអភិបាលកិច្ចមូលដ្ឋាន នៅមានកម្រិត។

- យុវជនប្រហែលពាក់កណ្តាល (៥១%) មិនបានដឹងថា ពួកគេមានសិទ្ធិចូលរួមក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់/ក្រុង-ស្រុក-ខណ្ឌនោះទេ។ ៥៩% មិនបានដឹងថា ពួកគេមានសិទ្ធិចូលរួមកិច្ចប្រជុំប្រចាំខែ សិក្ខាសាលា ឬវេទិកាផ្សេងៗដែលរៀបចំដោយអាជ្ញាធរមូលដ្ឋានឡើយ។ ភាគរយស្រដៀងគ្នានេះ (៥៨%) មិនបានដឹងថា ពួកគេមានសិទ្ធិអាចចូលរួមតាមដានការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់/ក្រុង-ស្រុក-ខណ្ឌបាននោះទេ។

## កម្រិតនៃការចូលរួមក្នុងកិច្ចអភិវឌ្ឍន៍មូលដ្ឋានក្នុងចំណោមយុវជន មានកម្រិតទាប។

- មានយុវជនតែ ១៦% ប៉ុណ្ណោះ ដែលធ្លាប់បានចូលរួមក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់/ក្រុង-ស្រុក-ខណ្ឌ។ ប្រហែល ម្នាក់ក្នុងចំណោមដប់នាក់ (១១%) ធ្លាប់បានចូលរួមកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាដែលរៀបចំដោយអាជ្ញាធរមូលដ្ឋាន ខណៈពេលដែលមានតែ ៩% ប៉ុណ្ណោះ ដែលធ្លាប់បានចូលរួមក្នុងការតាមដានការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់/ក្រុង-ស្រុក-ខណ្ឌ។

## ឧបសគ្គបីចម្បង ដែលរារាំងយុវជនមិនឱ្យចូលរួមក្នុងសកម្មភាពរបស់ពលរដ្ឋនៅក្នុងមូលដ្ឋានរួមមាន កង្វះការអញ្ជើញ កង្វះខាតព័ត៌មាន និងភាពមមាញឹករបស់យុវជន។

- នៅពេលសួរថាតើអ្វីដែលរារាំងពួកគេមិនឱ្យចូលរួមសកម្មភាពខាងលើ អ្នកឆ្លើយតប ៥៧% បាននិយាយថា ពីព្រោះពួកគេមិនត្រូវបានអញ្ជើញឱ្យចូលរួម។ ៥៤% បាននិយាយថា ពីព្រោះពួកគេពុំមានព័ត៌មានអំពីសកម្មភាពទាំងនោះ ខណៈពេលដែល ៤៦% បានលើកឡើងថា ភាពមមាញឹកគឺជាមូលហេតុចម្បង។

## កម្រិតនៃការចូលរួមផ្នែកនយោបាយក្នុងចំណោមយុវជនមានកម្រិតទាប។

- យុវជនម្នាក់ក្នុងចំណោមដប់នាក់ប៉ុណ្ណោះដែលធ្លាប់បានលើកឡើងអំពីតម្រូវការ ឬបញ្ហានានារបស់ពួកគេទៅកាន់មន្ត្រីសាធារណៈ។ មានយុវជនតែ ៤% ប៉ុណ្ណោះ ដែលបានចុះហត្ថលេខាគាំទ្រញត្តិ តាមអនឡាញ ឬក្រដាស។ យុវជន ៣% ធ្លាប់បានបរិច្ចាគប្រាក់សម្រាប់បុព្វហេតុនយោបាយ។ ហើយ ៥% ធ្លាប់បានចូលរួមក្នុងសកម្មភាពតវ៉ាផ្សេងៗ។ ប្រហែល ១២% ធ្លាប់បានចូលរួមយុទ្ធនាការឬការជួបជុំនយោបាយ។

## ចំណាប់អារម្មណ៍របស់យុវជនចំពោះកិច្ចការរដ្ឋាភិបាល និង សាធារណៈ មានកម្រិតទាប។

- ខណៈដែល ១៧% បាននិយាយថា ពួកគេចាប់អារម្មណ៍ ឬចាប់អារម្មណ៍យ៉ាងខ្លាំងលើកិច្ចការនយោបាយ ៨២% បានចង្អុលបង្ហាញថា ពួកគេមិនចាប់អារម្មណ៍ទាល់តែសោះ ឬចាប់អារម្មណ៍បន្តិចបន្តួចលើកិច្ចការនយោបាយ។ ការវិភាគបន្ថែមបង្ហាញថា យុវជនដែលមានការចាប់អារម្មណ៍លើនយោបាយច្រើនជាបុរស មានការអប់រំខ្ពស់ រស់នៅទីប្រជុំជន និងមានចំណូលក្នុងគ្រួសារខ្ពស់។

## ចំណេះដឹងទាបអំពីនយោបាយ គឺជាមូលហេតុចម្បងដែលរារាំងយុវជនភាគច្រើនមិនឱ្យចាប់អារម្មណ៍លើនយោបាយ។

## យុវជនច្រើនគួរសមយល់ថា នយោបាយជារឿងគ្រោះថ្នាក់។

- នៅពេលដែលអ្នកឆ្លើយតបការស្ទង់មតិទាំងនេះត្រូវបានស្នើសុំឱ្យផ្តល់មូលហេតុចម្បង ដែលពួកគេមិនចាប់អារម្មណ៍លើនយោបាយ ពីរភាគបី (៦៦%) បានលើកឡើងអំពីកង្វះខាតចំណេះដឹងអំពីនយោបាយ។ វ័យ(ក្មេងពេក) ត្រូវបានលើកឡើងដោយមួយភាគបីនៃយុវជនសរុប (៣៤%)។ លើសពីនេះ ជិតម្នាក់ក្នុងចំណោមប្រាំនាក់

(១៨%) បាននិយាយថា មូលហេតុគឺដោយសារពួកគេយល់ថានយោបាយជារឿងគ្រោះថ្នាក់។

**យុវជនភាគច្រើនមានចំណាប់អារម្មណ៍តិចតួចលើសារព័ត៌មាន។**

- យុវជនប្រហែល ៥៧ ភាគរយ (តិចជាងម្តងក្នុងមួយសប្តាហ៍) ឬមិនធ្លាប់តាមដានព័ត៌មានអំពីនយោបាយ ឬរដ្ឋាភិបាលនោះទេ។ ៣៧% បានតាមដានព័ត៌មានទាក់ទងនឹងប្រធានបទទាំងនេះម្តង ឬច្រើនដងក្នុងមួយសប្តាហ៍។ មានតែ ៥% ប៉ុណ្ណោះដែលបានអះអាងថាបានតាមដានព័ត៌មានជារៀងរាល់ថ្ងៃ។

**មានយុវជនតែមួយភាគតូចប៉ុណ្ណោះដែលបានពិភាក្សាអំពីនយោបាយនៅផ្ទះ ឬជាមួយមិត្តភ័ក្តិ។**

- យុវជន ៧៦% ភាគរយ ឬមិនធ្លាប់ពិភាក្សាអំពីនយោបាយជាមួយសមាជិកគ្រួសារ ឬមិត្តភក្តិនោះទេ។ ១៩% បានពិភាក្សាអំពីប្រធានបទនេះម្តងម្កាល ខណៈដែល ៥% បានចូលរួមក្នុងការពិភាក្សាជាញឹកញាប់ ឬជាទៀងទាត់។

**ទោះបីជាប្រព័ន្ធផ្សព្វផ្សាយសង្គមគឺជាផ្នែកមួយដែលមិនអាចខ្វះបាននៃជីវិតប្រចាំថ្ងៃរបស់យុវជនក្តី ក៏មានយុវជនតែភាគមួយតូចប៉ុណ្ណោះ ដែលបានប្រើវាដើម្បីបង្ហាញទស្សនៈរបស់ពួកគេអំពីនយោបាយ។**

- យុវជនម្នាក់ក្នុងចំណោមប្រាំនាក់ (២១%) ធ្លាប់បានបង្ហាញអំពីទស្សនៈនយោបាយតាមរយៈការបង្ហោះ ការចែករំលែក ឬបញ្ចេញមតិនៅលើវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គម។ ទោះបីជាយ៉ាងណាក៏ដោយ យុវជនភាគច្រើនលើសលុប (៧៩%) មិនធ្លាប់បានចូលរួមនៅក្នុងសកម្មភាពអនឡាញនេះទេ។

**អ្នកឆ្លើយតបសម្ភាសភាគច្រើនបានយល់ស្របថា យុវជនគួរតែទទួលបានតួនាទីជាអ្នកដឹកនាំកាន់តែច្រើនទៀតនៅគ្រប់កន្លែង**

- ៨៤% បានយល់ស្រប ឬយល់ស្របទាំងស្រុង ចំពោះការអះអាងថា យុវជនគួរតែទទួលបានតួនាទីជាអ្នកដឹកនាំកាន់តែច្រើនទៀត នៅក្នុងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**យុវជនជាច្រើនបានយល់ថា កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការលើកកម្ពស់ការចូលរួមតាមសិទ្ធិពលរដ្ឋ និងនយោបាយរបស់យុវជន នៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ។**

- យុវជនម្នាក់ក្នុងចំណោមបួននាក់ (២៥%) បានលើកឡើងថា គោលដៅនៃការធ្វើឱ្យយុវជនអាចចូលរួមយ៉ាងពេញលេញនៅក្នុងការអភិវឌ្ឍន៍សង្គម និងនយោបាយរបស់ប្រទេស ដូចមានចែងនៅក្នុងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន សម្រេចបានទាំងស្រុង ឬភាគច្រើន។ ប្រហែល ៤៦% បានយល់ឃើញថា សម្រេចបានមួយផ្នែក ឬតិចតួចបំផុត។ ហើយ ៣% ជឿថា មិនសម្រេចបានទាល់តែសោះ។

**នៅពេលនិយាយអំពីការចូលរួមផ្នែកនយោបាយរបស់ពលរដ្ឋ បញ្ហាបីចម្បងដែលយុវជនបានកំណត់ឃើញសម្រាប់ភាគីផ្គត់ផ្គង់ រួមមាន កង្វះខាតឱកាស (រួមទាំងបរិយាកាសនយោបាយមិនអំណោយផល និងកង្វះខាតយន្តការសម្រាប់ការចូលរួម) ហើយសម្រាប់ភាគីយុវជនផ្ទាល់ រួមមាន កង្វះចំណេះដឹងអំពីការចូលរួម និងកង្វះខាតសមត្ថភាពនិងធនធានក្នុងការចូលរួម។**

- យុវជនកម្ពុជាជិតម្នាក់ក្នុងចំណោមប្រាំនាក់ (២៤%) បានលើកឡើងថា កង្វះខាតឱកាសក្នុងការចូលរួម គឺជាបញ្ហាប្រឈមធំបំផុតចំពោះការចូលរួមតាមសិទ្ធិពលរដ្ឋរបស់យុវជន។ ២១% បានគិតថា ជាការខ្វះខាតចំណេះដឹងអំពីការចូលរួម។ ស្ទើរតែ ១៩% បានសម្គាល់ឃើញថា កង្វះខាតសមត្ថភាព និងធនធានក្នុងការចូលរួម ជាបញ្ហាសំខាន់។

### អនុសាសន៍៖

អ្នកជំនាញផ្នែកការចូលរួមនយោបាយរបស់ពលរដ្ឋ បានបង្ហាញមូលហេតុបីចម្បងៗ ដែលរារាំងប្រជាជនមិនឲ្យមានភាពសកម្មផ្នែកនយោបាយ៖ ពីព្រោះពួកគេមិនអាច ពីព្រោះពួកគេមិនចង់ និងពីព្រោះកង្វះអ្នកជួយជម្រុញ[៤]។ លទ្ធផលនៃការស្ទង់មតិនេះ គឺមានភាពស្របគ្នាទៅហ្នឹងទ្រឹស្តីនេះ។ អាស្រ័យហេតុនេះ អនុសាសន៍ត្រូវបានស្នើឡើងដូចខាងក្រោម៖

- រដ្ឋាភិបាលគួរតែកែលម្អក្របខ័ណ្ឌច្បាប់ គោលនយោបាយ និងបរិយាកាសនយោបាយសម្រាប់យុវជន ដើម្បីចូលរួមនៅក្នុងជីវិតសង្គម និងជីវិតផ្នែកនយោបាយរបស់ប្រទេស។ ការណ៍នេះទាមទារឱ្យមាន នៅក្នុងចំណោមកិច្ចការដទៃទៀត ការប្រកាន់ខ្ជាប់នូវសិទ្ធិពលរដ្ឋ និងសេរីភាពរបស់យុវជន ជាពិសេសសេរីភាពក្នុងការបញ្ចេញមតិ ការបង្កើតសមាគម និងការជួបជុំ ព្រមទាំងសិទ្ធិទទួលបានព័ត៌មានផងដែរ។ ការណ៍នេះក៏ចាំបាច់តម្រូវឲ្យមានការត្រួតពិនិត្យឡើងវិញ និងការកែសម្រួលច្បាប់ដែលមានស្រាប់ និងសេចក្តីព្រាងច្បាប់ដែលកំពុងមាន ឬអាចមានផលជះខ្លាំងទៅលើបរិយាកាសផ្នែកច្បាប់ និងនយោបាយសម្រាប់យុវជនក្នុងការចូលរួម រួមទាំងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (LANGO) សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត និងអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិផងដែរ។ សាលារដ្ឋ និងគ្រឹះស្ថានឧត្តមសិក្សាគួរតែបញ្ចូលវគ្គសិក្សាជាកាតព្វកិច្ចស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់ពលរដ្ឋ ហើយសិស្សនិស្សិតគួរតែត្រូវបានអនុញ្ញាតឱ្យពិភាក្សា និងជជែកវែកញែកអំពីការចូលរួមរបស់ពលរដ្ឋ និងនយោបាយដោយសេរីដូចដែលរដ្ឋធម្មនុញ្ញបានធានា។
- បង្កើត ធ្វើស្ថាប័នីយកម្ម និងគាំទ្រដល់រចនាសម្ព័ន្ធនានាសម្រាប់ការចូលរួមរបស់យុវជន និងការចូលរួមរបស់ពលរដ្ឋ។ ឧទាហរណ៍៖ ការគាំទ្រក្រុមប្រឹក្សាយុវជន ក្រុមប្រឹក្សានិស្សិត និងសហជីព សភាយុវជន និងស្ថាប័នសហគ្រប់គ្រង និងធានាថា ស្ថាប័នទាំងនេះដំណើរការនៅក្នុងមជ្ឈដ្ឋានដែលមានសេរីភាព សុវត្ថិភាព និងបរិយាប័ន្ន។
- ពង្រឹងសមត្ថភាព បណ្តាញ និងភាពជាដៃគូរបស់យុវជន។ វិធីមួយដែលអាចធ្វើទៅបានគឺ តាមរយៈការរៀបចំ និងអនុវត្តកម្មវិធីអប់រំ និងបណ្តុះបណ្តាលផ្លូវការ និងក្រៅផ្លូវការ ដែលជួយយុវជនអភិវឌ្ឍចំណាប់អារម្មណ៍ ចំណេះដឹង ជំនាញ និងគុណតម្លៃរយៈពេលវែងដែលចាំបាច់សម្រាប់ការចូលរួមរបស់ពលរដ្ឋ និងនយោបាយ។ វិធីមួយទៀតគឺ តាមរយៈការលើកកម្ពស់ និងគាំទ្រចលនា គំនិតផ្តួចផ្តើម និងបណ្តាញនៅកម្រិតមូលដ្ឋានដែលដឹកនាំដោយយុវជន។
- បង្កើត អនុវត្ត និងគាំទ្រកម្មវិធី និងគំនិតផ្តួចផ្តើមនានាដែលមានគោលបំណងជំរុញការស្ម័គ្រចិត្តរបស់យុវជន និងសេវាសហគមន៍ទូទាំងប្រទេស។
- អង្គការសង្គមស៊ីវិលគួរតែពិនិត្យឡើងវិញលើយុទ្ធសាស្ត្រទំនាក់ទំនង និងផលិតផលនៃការអប់រំរបស់ពួកគេ ដើម្បីបង្កើនចំណេះដឹង និងចំណាប់អារម្មណ៍របស់យុវជនលើអភិបាលកិច្ចល្អ ភាពជាពលរដ្ឋ និងការចូលរួមផ្នែកនយោបាយ។ ទន្ទឹមនឹងនោះ ពួកគេគួរតែពង្រីកកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយព័ត៌មានអំពីការអភិវឌ្ឍន៍នៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិដែលពាក់ព័ន្ធនឹងយុវជន ជាពិសេសយុវជនដែលមិនសូវត្រូវបានយកចិត្តទុកដាក់ ដោយពិចារណាអំពីភាពខុសគ្នានៃលក្ខណៈ និងកាលៈទេសៈរបស់ពួកគេ រួមទាំងកម្រិតនៃការអប់រំ និងឧបសគ្គរបស់ពួកគេផងដែរ។
- តួអង្គផ្សេងពីរដ្ឋាភិបាលដែលមានចំណាប់អារម្មណ៍លើការកែលម្អសុខុមាលភាពសង្គម នយោបាយ និងសេដ្ឋកិច្ចរបស់យុវជន គួរតែបន្តពង្រីកវិសាលភាពនៃការងារចូលរួមជាមួយយុវជនរបស់ពួកគេ ជាពិសេសតាមរយៈការជួយធានាថា ទស្សនៈរបស់យុវជនត្រូវបានយកមកពិចារណានៅក្នុងគោលនយោបាយ និងការសម្រេចចិត្តរបស់រដ្ឋាភិបាល។

[៤]Brady, H. E., Verba, S., និង Schlozman, K. L. (ឆ្នាំ១៩៩៥)។ លើសពីស្ថានភាពសេដ្ឋកិច្ចសង្គម(SES)៖ គម្រូធនធានសម្រាប់ការចូលរួមផ្នែកនយោបាយ។ ការពិនិត្យលើវិទ្យាសាស្ត្រនយោបាយសហរដ្ឋអាមេរិក ៨៩(២), ២៧១-២៩៤។

# ការចូលរួមរបស់ពលរដ្ឋ

## ភាគរយយុវជនដែលមិនដឹងថាពួកគេមានសិទ្ធិចូលរួម៖

**៥៩%** ចូលរួមកិច្ចប្រជុំប្រចាំខែ សិក្ខាសាលា ឬ វេទិកាផ្សេងៗ ដែលរៀបចំដោយអាជ្ញាធរមូលដ្ឋាន

**៥៨%** តាមដានការអនុវត្តផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់/ក្រុង-ស្រុក-ខណ្ឌ

**៥១%** ការរៀបចំផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់/ក្រុង ស្រុក ខណ្ឌ

## តើអ្នកធ្លាប់បានចូលរួមសកម្មភាពខាងក្រោមដែរឬទេ?




## មូលហេតុធំចំនួនពដែលយុវជនមិនបានចូលរួម ក្នុងសកម្មភាពសង្គម និងនយោបាយក្នុងមូលដ្ឋាន

**៥៧%** មិនបានទទួលការអញ្ជើញ ពីអាជ្ញាធរមូលដ្ឋាន

**៥៤%** កង្វះព័ត៌មានអំពីសកម្មភាព

**៤៦%** កង្វះពេលវេលា

## តើអ្នកធ្លាប់ចូលរួមសកម្មភាពខាងក្រោមដែរឬទេ?




## តើអ្នកមានការចាប់អារម្មណ៍លើរឿងនយោបាយកម្រិតណា?



### មូលហេតុចម្បងចំនួនដែលយុវជន "មិនចាប់អារម្មណ៍ទាល់តែសោះ" ឬ"ចាប់អារម្មណ៍តិចតួច" អំពីនយោបាយ

| | |
|---|---|
| នយោបាយគឺជារឿងគ្រោះថ្នាក់ | ១៨% |
| វាពុំមែនជាកិច្ចការរបស់ខ្ញុំដែលត្រូវគិតពីនយោបាយ | ៣១% |
| ខ្ញុំនៅក្មេងពេកមិនគួរចាប់អារម្មណ៍រឿងនយោបាយ | ៣៤% |
| ការយល់ដឹងទាបអំពីនយោបាយ | ៦៦% |

### ភាគរយយុវជនដែលបាននិយាយថាពួកគេ "ចាប់អារម្មណ៍ខ្លាំង" ឬ"ចាប់អារម្មណ៍ខ្លាំងណាស់" លើនយោបាយ ដោយបែងចែកតាមស្ថានភាពប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

| | |
|---|---|
| បុរស | ២០% |
| ស្ត្រី | ១៤% |
| ទីប្រជុំជន | ២២% |
| ជនបទ | ១៥% |
| ១៥-២៤ឆ្នាំ | ១៥% |
| ២៥-៣០ឆ្នាំ | ២០% |
| បឋមសិក្សា | ១០% |
| មធ្យមសិក្សា | ១៦% |
| ឧត្តមសិក្សា | ៣៩% |
| ចំណូលក្នុងគ្រួសារទាប | ១៥% |
| មធ្យម | ១២% |
| ខ្ពស់ | ២៣% |

### នៅពេលអ្នកជួបជុំជាមួយសមាជិកគ្រួសារ ឬមិត្តភក្តិ តើអ្នកពិភាក្សាគ្នាអំពីនយោបាយញឹកញាប់កម្រិតណា?

| | |
|---|---|
| ៥៨% | មិនដែលសោះ |
| ១៧% | កម្រ |
| ១៩% | យូរម្តង |
| ៥% | ញឹកញាប់ |

## តើអ្នកមានគណនីបណ្តាញសង្គមដែរឬទេ?




## តើបណ្តាញសង្គមណាមួយដែលអ្នកឧស្សាហ៍ប្រើប្រាស់ច្រើនជាងគេបំផុត?

- ៩០% Facebook
- ៤% YouTube
- 0.៤% Instagram
- ៤% Tik Tok
- ២% Telegram

## តើអ្នកតាមដានព័ត៌មាន មតិយោបល់ ការពិភាក្សាអំពីបញ្ហាសង្គម ឬនយោបាយ ដែលបង្ហោះដោយអ្នកប្រើប្រាស់ផ្សេងទៀត?



## តើអ្នកប្រើប្រាស់បណ្ដាញសង្គមញឹកញាប់កម្រិតណាដើម្បីបង្ហោះ ចែករំលែកបន្ត បញ្ចេញមតិយោបល់ ឬពិភាក្សាអំពីនយោបាយ និងរដ្ឋាភិបាល?




## តាមទស្សនៈរបស់អ្នក តើឧបសគ្គធំបំផុតដែលរារាំងយុវជនមិនឱ្យចូលរួមសកម្មភាពសង្គម ឬនយោបាយគឺជាអ្វី?

២៤% កង្វះឱកាសក្នុងការចូលរួម

២១% កង្វះចំណេះដឹងអំពីការចូលរួម

១៩% កង្វះសមត្ថភាព និងធនធានក្នុងការចូលរួម

## តើអ្នកយល់ស្របកម្រិតណាចំពោះការលើកឡើងថា "យុវជនគួរតែទទួលបានតួនាទីជាអ្នកដឹកនាំកាន់តែច្រើនទៀត ទាំងនៅរដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ"?




## គោលដៅសំខាន់មួយនៃគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍន៍យុវជន គឺផ្ដល់ឱកាសឱ្យយុវជនអាចចូលរួមពេញលេញក្នុងការអភិវឌ្ឍប្រទេសជាតិ។ តើអ្នកគិតថាគោលដៅនេះសម្រេចបានជោគជ័យកម្រិតណាហើយ?



# ស្ថានភាពសេដ្ឋកិច្ចរបស់យុវជន និងទស្សនៈយុវជនអំពីអនាគត

**យុវជនមានការព្រួយបារម្ភអំពីការបំពេញតម្រូវការចំណាយជាមូលដ្ឋាន។**

- យុវជនកម្ពុជា ៧៨% មានការព្រួយបារម្ភ ឬព្រួយបារម្ភយ៉ាងខ្លាំងអំពីការមិនមានថវិកាគ្រប់គ្រាន់ដើម្បីទូទាត់ថ្លៃព្យាបាលសម្រាប់ការថែទាំសុខភាពទូទៅបាន។ ភាគរយប្រហាក់ប្រហែលគ្នា (៧៨%) មានការព្រួយបារម្ភ ឬព្រួយបារម្ភយ៉ាងខ្លាំងអំពីការមិនអាចរក្សាបាននូវកម្រិតជីវភាពដែលពួកគេមានដូចពីមុន។ ប្រហែល ៦២% មានការព្រួយបារម្ភ ឬព្រួយបារម្ភយ៉ាងខ្លាំងអំពីការពុំមានថវិកាគ្រប់គ្រាន់សម្រាប់ទូទាត់ការចំណាយទូទៅប្រចាំខែរបស់ពួកគេ។ ក្នុងចំណោមសិស្សនិស្សិត ជិតមួយភាគបី (៣១%) បាននិយាយថា ពួកគេមានការព្រួយបារម្ភ ឬព្រួយបារម្ភយ៉ាងខ្លាំងអំពីការមិនមានថវិកាគ្រប់គ្រាន់សម្រាប់បង់ថ្លៃសិក្សារបស់ពួកគេ។

**អ្នកចូលរួមភាគច្រើនក្នុងការស្ទង់មតិ បានយល់ឃើញថា ស្ថានភាពរស់នៅរបស់ពួកគេមានភាពប្រសើរឡើង។ ទោះបីជាយ៉ាងណាក៏ដោយ យុវជនច្រើនគួរសម បានមើលឃើញថា កម្រិតជីវភាពរស់នៅរបស់ពួកគេមានការគំរាមកំហែង។**

- យុវជន ប្រហែលពីរភាគបី (៦៧%) មានអារម្មណ៍ថា ស្ថានភាពរស់នៅរបស់ពួកគេមានភាពប្រសើរឡើង ឬប្រសើរជាងមុនខ្លាំង បើធៀបនឹងប្រាំឆ្នាំមុន។ យ៉ាងណាក៏ដោយ មួយភាគបី (៣៣%) បានយល់ឃើញថា កម្រិតជីវភាពរស់នៅរបស់ពួកគេនៅដដែល ឬលំបាកជាងមុន។

**យុវជនមួយចំនួនធំមិនមានសេចក្តីក្លាហានក្នុងការរាយការណ៍អំពីភាពខ្វះខាតពាក់ព័ន្ធនឹងសេវាសាធារណៈ។**

- នៅពេលសួរថាតើពួកគេទំនងជានឹងចាត់វិធានការបែបណាដូចជា ការទាក់ទងទៅមន្ត្រី ឬរាយការណ៍អំពីបញ្ហានៅលើគណនីបណ្តាញផ្សព្វផ្សាយសង្គមរបស់ពួកគេជាដើម ប្រសិនបើពួកគេមិនពេញចិត្តនឹងសេវាសាធារណៈណាមួយ មានយុវជនតែម្នាក់ក្នុងចំណោមបួននាក់ប៉ុណ្ណោះ (២៥%) ដែលបង្ហាញថា ពួកគេប្រាកដជានឹងធ្វើ ឬប្រហែលជានឹងធ្វើដូច្នោះ ខណៈដែលយុវជនផ្សេងទៀត (៧៤%) បានឆ្លើយតបថា ពួកគេប្រហែលជាមិនធ្វើ ឬមិនធ្វើអ្វីម៉្យាងដូចសកម្មភាពខាងលើឡើយ។

**យុវជនមានសុទិដ្ឋិនិយមថា សេវាសាធារណៈនឹងផ្លាស់ប្តូរកាន់តែប្រសើរឡើងក្នុងរយៈពេលប្រាំឆ្នាំខាងមុខ។**

- ឧទាហរណ៍៖ យុវជនប្រាំបួនក្នុងចំណោមដប់នាក់ (៩០%) ដែលបានចូលរួមក្នុងការស្ទង់មតិ បានគិតថា វិស័យសុខាភិបាល អប់រំ និងការងារនឹងមានភាពប្រសើរឡើង ឬប្រសើរឡើងខ្លាំងក្នុងរយៈពេលប្រាំឆ្នាំខាងមុខ។

**យុវជនច្រើនគួរសមមិនសូវមានក្តីសង្ឃឹមលើអនាគតនោះទេ នៅពេលនិយាយអំពីការការពារធនធានធម្មជាតិ និងបរិស្ថាន។**

- ភាគរយនៃយុវជនដែលមានសុទិដ្ឋិនិយមថា ការការពារធនធានធម្មជាតិនឹងមានភាពប្រសើរឡើង ឬប្រសើរឡើងខ្លាំងក្នុងរយៈពេលប្រាំឆ្នាំខាងមុខ មានចំនួនតិចជាង (៧១%) ហើយ ២៤% ជឿថា បញ្ហានេះនឹងនៅដដែល ឬអាក្រក់ជាងនេះទៀត។

**ការកាត់បន្ថយអំពើពុករលួយបានស្ថិតនៅចំណុចកំពូលនៃរបៀបវារៈគោលនយោបាយយុវជនកម្ពុជាសម្រាប់រយៈពេលប្រាំឆ្នាំខាងមុខ។**

- ពាក់កណ្តាលនៃយុវជនកម្ពុជា (៥០%) បាននិយាយថា ការកាត់បន្ថយអំពើពុករលួយគួរតែជាអាទិភាពគោលនយោបាយទីមួយ របស់រាជរដ្ឋាភិបាល ក្នុងរយៈពេលប្រាំឆ្នាំខាងមុខ បន្ទាប់មកគឺ ការបង្កើនការងារ (៤៣%) ការកាត់បន្ថយភាពក្រីក្រ (៤០%) និងការបង្កើនគុណភាពនៃការអប់រំ (៣៨%)។

### អនុសាសន៍៖

- រដ្ឋាភិបាលគួរតែខិតខំប្រឹងប្រែងទ្វេដងក្នុងការកសាងភាពធន់ផ្នែកហិរញ្ញវត្ថុ និងលើកកម្ពស់សុខុមាលភាពផ្នែកហិរញ្ញវត្ថុរបស់យុវជន ដើម្បីធ្វើឱ្យពួកគេអាចបំពេញតម្រូវការទូទៅផ្នែកហិរញ្ញវត្ថុរបស់ពួកគេបាន។ ក្រុមសង្គមមួយចំនួនក្នុងចំណោមក្រុមយុវជនស័ក្តិសមនឹងទទួលបានការគាំទ្រខ្លាំងជាង ប្រសិនបើធៀបនឹងក្រុមដទៃទៀត ជាពិសេស ស្ត្រី និងយុវជននៅតាមជនបទ។
- រៀបចំសូចនាករដើម្បីតាមដានវឌ្ឍនភាពក្នុងការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន៖

  . ដើម្បីជួយសម្រួលដល់ការត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយ រដ្ឋាភិបាលគួរពិចារណាអនុវត្តវិធានការដូចតទៅ៖ (ក) ធ្វើបច្ចុប្បន្នភាពគោលដៅជាក់លាក់រយៈពេលខ្លី និងមធ្យមសម្រាប់គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន (ខ) រៀបចំសូចនាករដ៏រឹងមាំដើម្បីវាយតម្លៃថាតើ និងនៅពេលណាដែលគោលដៅទាំងនោះត្រូវបានសម្រេចដោយជោគជ័យ និង(គ) អនុវត្ត ឬផ្តល់ការគាំទ្រដល់ការវាស់ស្ទង់គ្រប់ជ្រុងជ្រោយលើសូចនាករទាំងនោះ។ ប្រសិនបើធនធានមានកម្រិត វាមានសារសំខាន់ដែលគោលដៅគោលនយោបាយត្រូវបានផ្តល់អាទិភាព។

- ការវាស់ស្ទង់វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយតម្រូវឱ្យមានការកសាងប្រព័ន្ធ ដែលអាចបង្កើត រក្សាទុក និងវិភាគទិន្នន័យ ព្រមទាំងភ័ស្តុតាងអំពីស្ថានភាពយុវជនទាក់ទងនឹងការងារ សុខភាព ការអប់រំ និងការចូលរួមរបស់ពលរដ្ឋ បានយ៉ាងមានប្រសិទ្ធភាព។ ភ័ស្តុតាង និងទិន្នន័យ ជាលទ្ធផល អាចជួយផ្តល់ព័ត៌មានដល់អ្នកបង្កើតគោលនយោបាយក្នុងការរៀបចំយុទ្ធសាស្ត្រ និងគោលនយោបាយថ្មីៗទាក់ទងនឹងយុវជន ឬកែលម្អគោលនយោបាយដែលមានស្រាប់។
- រដ្ឋាភិបាលគួរតែបង្កើនការប្តេជ្ញាចិត្ត និងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការទប់ស្កាត់អំពើពុករលួយ និងលើកកម្ពស់អភិបាលកិច្ចល្អ រួមទាំងការអនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ច្បាប់ស្តីពីការការពារបុគ្គលរាយការណ៍ និងច្បាប់ស្តីពីការការពារអ្នកជំនាញ ជនរងគ្រោះ និងសាក្សី ហើយធានាថា ច្បាប់ទាំងនេះស្រមតាមស្តង់ដារអន្តរជាតិដែលអាចទទួលយកបាន។
- កសាងសមត្ថភាព និងទំនុកចិត្ត ព្រមទាំងបរិយាកាសអំណោយផលសម្រាប់យុវជន ក្នុងការបញ្ចេញមតិរបស់ពួកគេអំពីកិច្ចការពលរដ្ឋ និងនយោបាយ រួមទាំងសេវាសាធារណៈផងដែរ ហើយធានាថាមតិយោបល់របស់ពួកគេត្រូវបានយកមកប្រើប្រាស់។

## ស្ថានភាពសេដ្ឋកិច្ចរបស់យុវជន និងទស្សនៈយុវជនអំពីអនាគត

### បើប្រៀបនឹងពេល៥ឆ្នាំមុន តើអ្នកគិតថាស្ថានភាពរស់នៅរបស់អ្នកក្នុងពេលឥឡូវនេះមានលក្ខណៈដូចម្តេច?

| ៦៧% ប្រសើរជាងមុន | ១៨% នៅដដែល | ១៥% ធ្លាក់ចុះ |
|---|---|---|



**៧៨%**
បារម្ភមិនមានថវិកាគ្រប់គ្រាន់សម្រាប់ថៃទាំសុខភាពពេលឈឺថ្កាត់។



**៦២%**
បារម្ភមិនមានលុយគ្រប់គ្រាន់សម្រាប់ការចំណាយប្រចាំខែ។



**៧៨%**
បារម្ភមិនអាចរក្សាកម្រិតជីវភាពរស់នៅដូចពីមុន។



**ជិត ១ ក្នុងចំណោម ៣ នាក់(៣០%):**
បារម្ភមិនមានលុយសម្រាប់បង់ថ្លៃការសិក្សា។

### ប្រសិនបើអ្នកមិនពេញចិត្តនឹងសេវាសាធារណៈណាមួយ តើអ្នកទំនងនឹងធ្វើរឿងនេះកម្រិតណា៖ ដូចជាទាក់ទងទៅមន្ត្រីរដ្ឋ ឬស្ថាប័នពាក់ព័ន្ធ ឬបង្ហោះក្នុងគណនីសង្គមផ្ទាល់ខ្លួន?

| ៥៩% | ១៥% | ១៩% | ៦% |
|---|---|---|---|
| មិនធ្វើទេ | ប្រហែលមិនធ្វើទេ | ប្រហែលនឹងធ្វើ | ប្រាកដជាធ្វើ |

### នៅពេលគិតពីអនាគត តើអ្នកគិតថាស្ថានភាពវិស័យខាងក្រោមនេះនឹងមានការប្រែប្រួលបែបណា ក្នុងរយៈពេល ៥ឆ្នាំទៅមុខ?




### សកម្មភាពចម្បងចំនួនពដែលរដ្ឋាភិបាលគួរតែផ្តោតជាអាទិភាពក្នុងរយៈពេល៥ឆ្នាំខាងមុខ៖

១ — ៥០% ការកាត់បន្ថយអំពើពុករលួយ

២ — ៤៣% ការបង្កើនការងារ

៣ — ៤០% ការបន្ថយភាពក្រីក្រ

## សេចក្តីសន្និដ្ឋាន

ការសិក្សានេះបង្ហាញអំពីសារសំខាន់នៃការស្តាប់ទស្សនៈរបស់យុវជន និងមនុស្សជំនាន់ក្រោយនៅកម្ពុជា។ ប្រទេសកម្ពុជាពុំមានកង្វះខាតនៃគំនិត និងឧបករណ៍ផ្នែកគោលនយោបាយដែលសំដៅដោះស្រាយបញ្ហា និងតម្រូវការរបស់យុវជន និងលើកកម្ពស់ការអភិវឌ្ឍសង្គមកិច្ច សេដ្ឋកិច្ច និងនយោបាយរបស់ពួកគេនោះទេ។ ប៉ុន្តែ ប្រសិនបើយុវជនមានអារម្មណ៍ថា ការអនុវត្តគោលនយោបាយទាំងអស់នៅមានកម្រិត ឬថាពួកគេជួបប្រទះបញ្ហាប្រឈមក្នុងការទទួលបានសេវាសាធារណៈជាមូលដ្ឋាន និងអត្ថប្រយោជន៍ផ្សេងទៀតនៅពេលដែលពួកគេត្រូវការនោះ គោលនយោបាយទាំងនោះនឹងមិនទាន់មានប្រសិទ្ធភាពតាមការគួរនោះទេ។ ដូចនេះ រដ្ឋាភិបាលគួរតែបញ្ជាក់ឡើងវិញអំពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការប្រែក្លាយគោលនយោបាយយុវជនឱ្យទៅជាសកម្មភាពជាក់ស្តែង និងដើម្បីសម្រេចបាននូវគោលដៅនៃការលើកកម្ពស់សមាហរណកម្មពេញលេញរបស់យុវជនទៅក្នុងជីវិតផ្នែកសង្គមកិច្ច សេដ្ឋកិច្ច និងនយោបាយរបស់ប្រទេសកម្ពុជា។

សហភាពអឺរ៉ុប

ស៊ុយអែត
Sverige

របាយការណ៍សង្ខេបនេះត្រូវបានសរសេរដោយ៖ ជុនលី សិរីវិចិត្រ, ខេង រដ្ឋា, អ៊ឹម នរិន្ទ និង ប៊ុច ពិសី។ សូមចូលទៅគេហទំព័រ៖ www.ticambodia.org ដើម្បីទាញយកឯកសារនេះ។

**អង្គការតម្លាភាពកម្ពុជា**
ផ្ទះលេខ១៣ ផ្លូវ៥៥៤ សង្កាត់បឹងកក់១ ខណ្ឌទួលគោក ១២០៤០៧ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ (+៨៥៥) ២៣ ៨៨៣ ៦៨១ | (+៨៥៥) ២៣ ៨៨៣ ៦៨២
គេហទំព័រ៖ www.ticambodia.org
គេហទំព័រការិយាល័យកណ្តាល: www.transparency.org

ឯកសារនេះត្រូវបានផលិតតាមរយៈជំនួយហិរញ្ញវត្ថុពីសហភាពអឺរ៉ុប (EU) និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida)។ រាល់ខ្លឹមសារនៅក្នុងឯកសារនេះគឺជាការទទួលខុសត្រូវទាំងស្រុងរបស់អង្គការតម្លាភាពកម្ពុជា និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ម្ចាស់ជំនួយឡើយ។